## ពេលវេលាសមស្របសម្រាប់សវនាការ (reasonable time for trial)

ការទាមទារនេះ ក្នុងមូលហេតុថា កាលណាមានការអូសបន្លាយពេលវេលា ក្នុងការធ្វើសវនាការ វានាំឲ្យមានការបំពានយុត្តិធម៌ (abuse of justice) ពិបាកផានាយុត្តិធម៌ នាពេលដែលភស្តុតាង (evidence) និងសាក្សី (witness) មួយចំនួន ក្លាយជាមិនអាចទុកចិត្តបាន។ នេះនឹងប៉ះពាល់ដល់សវនាការប្រកបដោយយុត្តិធម៌ (fair trial)។

តាមការអនុវត្ត ការយឺតយ៉ាវអាចបណ្តាលមកពី មេធាវីការពារក្តី ក្នុងការប្រមូលភស្តុតាង (evidence)។ ការយឺតយ៉ាវបណ្តាលឲ្យមាន សំណុំរឿងកកស្ទះ ជាលទ្ធផលរដ្ឋអាជ្ញា និងជនត្រូវចោទអាចប្រកាន់យកនីតិវិធីទទួលយកពិរុទ្ធភាព(guilty plea)។ នេះក្នុងគោលបំណងដើម្បីទទួលបានការ ចោទប្រកាន់នូវបទល្មើសស្រាលជាង (lesser charge) ដែលករណីខ្លះ ជនត្រូវចោទ ជាជនគ្មានទោស (innocent) (David Robertson, dictionary of human rights, 2004, 2nd Ed., p. 191)។

**ខ្លឹមសារបន្ថែម៖** ការយឺតយ៉ាវនៃសវនាការ នេះកើតឡើងនៅប្រទេសជាច្រើន រួមទាំងក្នុងប្រទេសអភិវឌ្ឍន៍។តាមយុត្តិសាស្ត្រ រយៈពេលសមស្រប ឬមិន ត្រូវបានគិតចាប់តាំងពីពេលឃាត់ខ្លួន (បើមាន) រហូតដល់ថ្ងៃបញ្ចប់សវនាការប្រកាសពិរុទ្ធភាព។ ការយឺតយ៉ាវ វាផ្អែកទៅតាមសំណុំរឿង មានភាពស្មុគ្រស្មាញឬក៏គ្មាន។ ក្នុងករណីខ្លះ មានភាពយឺតយ៉ាវយូរ ក៏ប៉ុន្តែមិនត្រូវបានរកឃើញថា មានការបំពានសិទ្ធិទទួលបានការវិនិច្ឆ័យសេចក្តីក្នុងវេលាសមស្របទេ (right to trial within reasonable time) ដោយសារភាពយឺតយ៉ាវនោះបណ្តាលមកពីភាពស្មុគ្រស្មាញនៃការស៊ើបអង្កេត ឬ យឺតយ៉ាវដោយសារជនត្រូវចោទខ្លួនឯង។